**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៣.សសរ**

# សេចក្ដីសម្រេច

## ស្ដីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

| | | |
|---|---|---|
| ១- ឯកឧត្ដម **គាត ឈន់** | ឧបនាយករដ្ឋមន្ត្រីប្រចាំការ | ប្រធាន |
| ២- ឯកឧត្ដម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្ដម **ជា ចាន់តូ** | ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្ដម **ហ៊ាន សាហ៊ីប** | អនុប្រធាននៃឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អនុប្រធាន |
| ៥- ឯកឧត្ដមទេសរដ្ឋមន្ត្រី **អ៊ឹម ឈុនលឹម** | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ | សមាជិក |
| ៦- ឯកឧត្ដមទេសរដ្ឋមន្ត្រី **ឆាយ ថន** | រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |



www.pheakdeylaw.com

| | | |
|---|---|---|
| ៧- ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨- ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០- ឯកឧត្តម **ស៊ុយ សែម** | រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១១- ឯកឧត្តម **លឹម គានហោ** | រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១២- ឯកឧត្តម **ត្រាំ សុខុន** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៣-ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៤- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៥- ឯកឧត្តមរដ្ឋមន្ត្រី **សុខ ចិន្តាសោភា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៦- ឯកឧត្តម **ហ៊ុន ម៉ានី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៧-ឯកឧត្តម **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ២.-**

ឯកឧត្តម **វ៉ាន់ ផល្លា** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com